

ក្រុមការងារគម្រោងគំនិតផ្តួចផ្តើមឱ្យមានការផ្លាស់ប្តូរនៅកម្ពុជា
កម្មវិធីបណ្តុះបណ្តាលអន្តរជាតិ ស្តីពីការអភិវឌ្ឍន៍ប្រព័ន្ធផ្សព្វផ្សាយនៅក្នុង
ក្របខ័ណ្ឌប្រជាធិបតេយ្យក្នុងតំបន់អាស៊ីឆ្នាំ២០២០

# គោលការណ៍ណែនាំស្តីពីការរាយការណ៍ ដែលគោរពតាមសមភាពយេនឌ័រ

ឯកសារពេញលេញ
ឆ្នាំ២០២១

# មាតិកា

មាតិកា..........................................................................១

សេចក្តីប្រកាសការគាំទ្រ........................................២

សេចក្តីថ្លែងអំណរគុណ..........................................៣

សេចក្តីផ្តើម.......................................................................៤

វត្ថុបំណង............................................................................៦

គោលការណ៍ណែនាំស្តីពីការរាយការណ៍

ដែលគោរពតាមសមភាពយេនឌ័រ...................៧



# សេចក្តីប្រកាសការគាំទ្រ

គោលការណ៍ណែនាំស្តីពីការរាយការណ៍ដែលគោរពតាម

សមភាពយេនឌ័រនេះត្រូវបានចូលរួមគាំទ្រដោយ៖

ខេមបូចា CambojA

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា Cambodian Center for Human Rights

មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ CCIM cambodian center for independent media

CfJ Cambodian Female Journalists

GADC អង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា Gender and Development for Cambodia

តម្លាភាពកម្ពុជា Transparency International Cambodia

វាយោ VAYO FM

VOD VODHOTNEWS.COM

មជ្ឈមណ្ឌលព័ត៌មានស្ត្រីកម្ពុជា Women's Media Centre of Cambodia

# សេចក្តីថ្លែងអំណរគុណ

គោលការណ៍ណែនាំនេះ ត្រូវបានផលិតឡើងដោយ ក្រុមការងារគម្រោងគំនិតផ្តួចផ្តើមឱ្យមានការផ្លាស់ប្តូរនៅកម្ពុជា ដែលដឹកនាំដោយលោក ជា សីង្ហតារាឫទ្ធិ អ្នកស្រី ហង្ស សម្ផស្ស លោក រស់ សារ៉ាត់ កញ្ញា សេង ស្រីភាព អ្នកស្រី កាន់ វិច្ឆិកា និង អ្នកស្រី គុច ណារ៉េន ដោយមានការសម្របសម្រួលពីលោក ស៊ុន ណារិន ដែលជាអ្នកសម្របសម្រួលកម្មវិធីបណ្តុះបណ្តាលអន្តរជាតិប្រចាំប្រទេសកម្ពុជា។ គម្រោងគំនិតផ្តួចផ្តើមឱ្យមានការផ្លាស់ប្តូរនេះ គឺជាផ្នែកមួយនៃកម្មវិធីបណ្តុះបណ្តាលអន្តរជាតិស្តីពីការអភិវឌ្ឍន៍ប្រព័ន្ធផ្សព្វផ្សាយនៅក្នុងក្របខ័ណ្ឌប្រជាធិបតេយ្យក្នុងតំបន់អាស៊ីឆ្នាំ២០២០ ។


លោក ជា សីង្ហតារាឫទ្ធិ


អ្នកស្រី ហង្ស សម្ផស្ស


លោក រស់ សារ៉ាត់


កញ្ញា សេង ស្រីភាព


អ្នកស្រី កាន់ វិច្ឆិកា


អ្នកស្រី គុច ណារ៉េន


លោក ស៊ុន ណារិន

គោលការណ៍ណែនាំនេះ អាចបង្កើតឡើងបានដោយមានការគាំទ្រពី ក្រុមការងារ នីរ៉ាស (NIRAS) ដែលដឹកនាំដោយអ្នកស្រី ខារ៉ូលីណា ហ្យេមប៊ី (Carolina Jemsby) និងអ្នកស្រី ម៉ារី ណេសឺរ (Marie Neese) ក៏ដូចជា អ្នកណែនាំផ្នែកប្រធានបទដែលមាន អ្នកស្រី អ៊ីមីលី ឡេម៉ង-យ៉ាកូបសិន (Emilie Lehmann-Jacobsen) និងអ្នកស្រី អានីតា សូឌឺប៊ែក យ៉ាកូបសិន (Agneta Söderberg Jacobson) និងការគាំទ្រពីទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍអន្តរជាតិស៊ុយអែត ដែលបានជួយគាំទ្រ និងផ្តល់មូលនិធិសម្រាប់កម្មវិធីបណ្តុះបណ្តាលអន្តរជាតិនេះ ។ យើងខ្ញុំសូមថ្លែងអំណរគុណជាអនេកចំពោះការគាំទ្រយ៉ាងពេញទំហឹង និងការណែនាំដ៏យកចិត្តទុកដាក់របស់ពួកគាត់ តាំងពីពេលចាប់ផ្តើមនៃគម្រោង ។

យើងខ្ញុំក៏សូមថ្លែងអំណរគុណដល់ក្រុមការងាររបស់អង្គការ NGO-CEDAW រួមមានអ្នកស្រី ជឹម ចាន់នាង និងអ្នកស្រី ដាណា វ៉ាលលែក (Dana Wallack) ចំពោះការរួមចំណែក ក៏ដូចជាការណែនាំអំពីទិដ្ឋភាពយេនឌ័រដើម្បីដាក់ក្នុងគោលការណ៍ណែនាំស្តីពីការរាយការណ៍ដែលគោរពតាមគោលការណ៍សមភាពយេនឌ័រនេះ ។

គោលការណ៍ណែនាំនេះ ក៏មិនអាចបង្កើតឡើងបានដែរ ប្រសិនបើគ្មានការចូលរួមពីអ្នកជំនាញក្នុងវិស័យសារព័ត៌មាន មន្ត្រីរដ្ឋាភិបាល និងតំណាងអង្គការសង្គមស៊ីវិល ចំនួន៣៤នាក់ ដែលបានចំណាយពេលវេលាចូលរួម និងផ្តល់ធាតុចូលដ៏មានតម្លៃ តាមរយៈសិក្ខាសាលាពិគ្រោះយោបល់សម្រាប់គោលការណ៍នេះ ។

# សេចក្តីផ្តើម

## ២.១ តើអ្វីទៅជាយេនឌ័រ?

បើយោងទៅតាមអង្គការសហប្រជាជាតិ "យេនឌ័រ" សំដៅទៅលើចំណែកលក្ខណៈសង្គម និងឱកាសសង្គម ដែលពាក់ព័ន្ធទៅនឹងភាពជាមនុស្សស្រី មនុស្សប្រុស និងភេទដទៃទៀត និងទំនាក់ទំនងរវាងបុរសនិងស្ត្រី ឬក្មេងប្រុស និងក្មេងស្រី ក៏ដូចជាទំនាក់ទំនងក្នុងចំណោមស្ត្រី និងបុរសផងដែរ។ លក្ខណៈ ឱកាស និងទំនាក់ទំនងទាំងអស់នេះ ត្រូវបានបង្កើតឡើងដោយសង្គម ហើយផ្សព្វផ្សាយតាមរយៈដំណើរការសង្គមនីយកម្ម។ និយមន័យយេនឌ័រមានភាពជាក់លាក់ និងអាចនឹងប្រែប្រួល ទៅតាមបរិបទណាមួយ និងពេលវេលាណាមួយ។ យេនឌ័រ កំណត់នូវអ្វីដែលត្រូវបានរំពឹងទុក អ្វីដែលត្រូវបានអនុញ្ញាត និងអ្វីដែលត្រូវបានផ្តល់តម្លៃ ទៅដល់ស្ត្រីណាម្នាក់ ឬក៏បុរសណាម្នាក់ នៅក្នុងបរិបទណាមួយ។ យេនឌ័រ គឺជាផ្នែកមួយនៃបរិបទវប្បធម៌សង្គមដ៏ទូលំទូលាយ។ លក្ខណៈវិនិច្ឆ័យសំខាន់ផ្សេងៗទៀតសម្រាប់ការវិភាគបរិបទវប្បធម៌សង្គមរួមមាន៖ វណ្ណៈ ពូជសាសន៍ កម្រិតនៃ ភាពក្រីក្រ ក្រុមជាតិពន្ធុ និងអាយុ។

នៅក្នុងសង្គមភាគច្រើន មានភាពខុសប្លែកគ្នា និងមានវិសមភាពនានា រវាងបុរសនិងស្ត្រី ចំពោះទំនួលខុសត្រូវដែលបានផ្តល់ឱ្យ ចំពោះសកម្មភាព ចំពោះការទទួលបាន និងកម្មសិទ្ធទៅលើធនធាននានា ក៏ដូចជាទៅលើឱកាសក្នុងការធ្វើសេចក្តីសម្រេចចិត្ត។ បុគ្គលគ្រប់រូប និងគ្រប់ភេទ មានសិទ្ធិជាមូលដ្ឋាន រួមទាំងសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងសិទ្ធិក្នុងការចូលរួមនៅគ្រប់កម្រិតនៃសង្គម។ ការលុបបំបាត់នូវផ្នត់គំនិតយេនឌ័របែបអវិជ្ជមាន គឺចាំបាច់ដើម្បីលើកកម្ពស់សមភាពយេនឌ័រពេញលេញនៅក្នុងសង្គម។ សមភាពពេញលេញ មានន័យថាសមភាពក្នុងការអនុវត្តជាក់ស្តែង មិនមែនគ្រាន់តែជាគោលនយោបាយនោះទេ ហើយនេះគឺជាសមភាពដែលមនុស្សគ្រប់គ្នាចង់បាន។



Photo courtesy to Rehash Trash women's empowerment project, Credit: Antal-Gabelics

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាចែងថា «គ្រប់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីត្រូវតែលុបបំបាត់។ ការកេងប្រវ័ញ្ចលើស្ត្រីក្នុងកន្លែងការងារត្រូវហាមឃាត់។ បុរស និងស្ត្រីមានសិទ្ធិស្មើគ្នាលើគ្រប់វិស័យជាពិសេសទាក់ទងនឹងអាពាហ៍ពិពាហ៍ និងបញ្ហាគ្រួសារ ... » (មាត្រា ៤៥) ។

## ២.២ តើប្រព័ន្ធផ្សព្វផ្សាយមានតួនាទីអ្វីខ្លះក្នុងការលើកកម្ពស់សមភាពយេនឌ័រ?

ប្រព័ន្ធផ្សព្វផ្សាយដើរតួនាទីយ៉ាងសំខាន់នៅក្នុងសង្គម ដូចជា រាយការណ៍អំពីព្រឹត្តិការណ៍ដែលកំពុងកើតឡើងផ្តល់ក្របខ័ណ្ឌសម្រាប់ការបកស្រាយ លើកឡើងអំពីបញ្ហាផ្សេងៗទាក់ទងនឹងប្រជាពលរដ្ឋ ផលិត និងផ្សព្វផ្សាយបន្តអំពីភាពអស្ចារ្យខាងផ្នែកសិល្បៈ វប្បធម៌ សង្គម ក៏ដូចជាសម្រាប់ការកម្សាន្ត (Llanos and Nina, 2011)។ ដូចនេះពិតណាស់ ប្រព័ន្ធផ្សព្វផ្សាយជាតួអង្គដ៏សំខាន់ក្នុងការលើកកម្ពស់សមភាពយេនឌ័រ ទាំងនៅក្នុងបរិយាកាសការងារ (ទាក់ទងនឹងការលើកកម្ពស់បុគ្គលិកជាស្ត្រីនៅក្នុងការងារគ្រប់ជាន់ថ្នាក់) និងភាពជាតំណាងរបស់ស្ត្រី និងបុរស (ទាក់ទងនឹងការបង្ហាញសមភាពយេនឌ័រប្រកបដោយយុត្តិធម៌ និងការប្រើប្រាស់ភាសា ឬពាក្យពេចន៍ប្រកបដោយអព្យាក្រឹតមិនលម្អៀងទៅលើយេនឌ័រណាមួយ)។

## ២.៣ តើអ្វីទៅជាការរាយការណ៍ដែលគោរពតាមគោលការណ៍យេនឌ័រ?

យោងតាមអង្គការយូណេស្កូ (UNESCO) ដើម្បីឱ្យប្រព័ន្ធផ្សព្វផ្សាយធ្វើការឆ្លុះបញ្ចាំងពីសង្គមមួយឱ្យបានត្រឹមត្រូវ និងធ្វើការផ្សព្វផ្សាយឱ្យបានពេញលេញ និងមានលក្ខណៈចម្រុះ ពិតណាស់ សារព័ត៌មានត្រូវបង្ហាញពីពិភពមួយ ដែលមើលពីកែវភ្នែកស្ត្រី និងបុរស។ ស្ត្រីគួរត្រូវបានចូលរួមនៅគ្រប់កម្រិត ក្នុងអង្គភាពសារព័ត៌មាន ចាប់តាំងពីតំណែងជាអ្នករាយការណ៍ព័ត៌មាន រហូតដល់តំណែងជាអ្នកធ្វើការសម្រេចចិត្ត។ នៅក្នុងរបាយការណ៍របស់ Luba Kassova ស្តីពី «ការមិនបញ្ចូលទស្សនៈរបស់ស្ត្រី នៅក្នុងអត្ថបទសារព័ត៌មាន» បានរកឃើញថា ការបាត់បង់ភាពជាតំណាងរបស់ស្ត្រីនៅក្នុងសារព័ត៌មាន ត្រូវបានលើកឡើងតាមរយៈសូចនាករសំខាន់ៗចំនួន ៤ រួមមាន៖ ១) ចំនួនស្ត្រីនៅក្នុងអង្គភាពសារព័ត៌មាន ២) ចំនួនស្ត្រីនៅក្នុងការចុះទៅយកព័ត៌មាន ៣) ចំនួនវីរជនដែលជាស្ត្រីនៅក្នុងអត្ថបទសារព័ត៌មាន និង ៤) ចំនួនព័ត៌មានផ្តោតទៅលើសមភាពយេនឌ័រ។ សម្រាប់ប្រទេសកម្ពុជា បើយោងទៅតាមការសិក្សាអំពីទិដ្ឋភាពយេនឌ័រនៅក្នុងប្រព័ន្ធផ្សព្វផ្សាយ (ប្រទេសកម្ពុជា) ដែលធ្វើឡើងដោយវិទ្យាស្ថានប្រព័ន្ធផ្សព្វផ្សាយហ្វូយូ (FOJO) ក្នុងឆ្នាំ២០១៨ បានបង្ហាញថា បុរសមានចំនួនច្រើនជាងស្ត្រីធ្វើការនៅក្នុងប្រព័ន្ធផ្សព្វផ្សាយ រួមទាំងក្នុងមុខតំណែងគ្រប់គ្រង ហើយអ្នកសារព័ត៌មានជាស្ត្រី បានជួបប្រទះនឹងការបៀតបៀននៅពេលដែលពួកគាត់កំពុងបំពេញការងារ ។

យ៉ាងណាមិញ ការដែលមានចំនួនស្ត្រីច្រើននៅក្នុងស្ថាប័នសារព័ត៌មានតែមួយមុខ គឺមិនទាន់គ្រប់គ្រាន់ដើម្បីធានាការរាយការណ៍ដែលគោរពតាមគោលការណ៍យេនឌ័រនៅឡើយទេ។ របៀបនៅក្នុងការជ្រើសរើសមុំនៃព័ត៌មាន និងរបៀបក្នុងការរាយការណ៍ គួរតែមានការផ្លាស់ប្តូរ។ អ្នកសារព័ត៌មានគួរដកស្រង់សម្តីរបស់ស្ត្រីជាប្រភពព័ត៌មានឱ្យបានច្រើនក្នុងនាមជាអ្នកផ្តល់មតិយោបល់ និងជាអ្នកជំនាញទៅលើវិស័យអ្វីមួយ។ នៅប្រទេសកម្ពុជា ស្ត្រីមានចំនួនប្រមាណជាងពាក់កណ្តាលនៃចំនួនប្រជាពលរដ្ឋសរុប ដែលជាសំឡេង និងកម្លាំង ពុំអាចមើលរំលងសម្រាប់ចរន្តសេដ្ឋកិច្ច និងសង្គមកិច្ចរបស់ប្រទេសជាតិ។ សរុបមក ទាំងបុរស និងស្ត្រី មានតួនាទីសំខាន់ដូចគ្នា ដែលមិនអាចខ្វះបាន ហើយបុគ្គលគ្រប់រូបគួរចៀសវាងការបែងចែកណាមួយទាក់ទងនឹងយេនឌ័រ។ អ្នកសារព័ត៌មានស្ត្រី និងបុរស អាចដើរតួនាទីក្នុងការផ្លាស់ប្តូរឥរិយាបទសាធារណជនចំពោះស្ត្រី និងផ្លាស់ប្តូរផ្នត់គំនិតចាស់គំរិល ទាក់ទងនឹងយេនឌ័រ ដែលមានពីមុនមក។

# វត្ថុបំណង

គោលការណ៍ណែនាំស្តីពី ការរាយការណ៍ដែលគោរពតាមសមភាពយេនឌ័រនេះ ត្រូវបានបង្កើតឡើងដើម្បីគាំទ្រដល់ប្រព័ន្ធផ្សព្វផ្សាយក្នុងកិច្ចប្រឹងប្រែងរបស់ខ្លួនក្នុងការពិពណ៌នាខ្លឹមសារព័ត៌មាននៅកម្ពុជា លើកកម្ពស់ សមភាពយេនឌ័រ ក៏ដូចជាឆ្លើយតបទៅនឹងតម្រូវការយេនឌ័រឱ្យកាន់តែប្រសើរឡើង។ គោលការណ៍ណែនាំនេះ នឹងរួមចំណែកដល់ការរាយការណ៍ ដែលប្រកបដោយបរិយាបន្ន និងសមភាព ដោយបង្ហាញពីតម្លៃ បទពិសោធន៍ អំណាច និងតម្រូវការរបស់មនុស្សគ្រប់រូបឱ្យបានស្មើគ្នា ទាំងស្ត្រី ក្មេងស្រី ក្មេងប្រុស បុរស និងអ្នកផ្សេងទៀតដែលស្ថិតក្នុងក្រុមដែលមិនត្រូវបានយកចិត្តទុកដាក់ ។

ជាមួយនឹងគោលការណ៍ណែនាំនេះដែរ យើងរំពឹងថាការបង្ហាញ និងការផ្តល់សិទ្ធិអំណាចបែបវិជ្ជមានដល់ស្ត្រី នឹងមានកាន់តែច្រើនឡើង នៅក្នុងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានគ្រប់ប្រភេទនៅប្រទេសកម្ពុជា។ ដូច្នេះគោលការណ៍ណែនាំនេះ ក៏នឹងអាចរួមចំណែកដល់ការកាត់បន្ថយវិសមភាព ការបន្ទុចបង្អាក់លើស្ត្រី និងជនងាយរងគ្រោះនៅក្នុងសង្គមកម្ពុជាផងដែរ ។



Photo courtesy to Voice of Democracy (VOD)

# គោលការណ៍ណែនាំស្តីពីការរាយការណ៍ ដែលគោរពតាមសមភាពយេនឌ័រ

គោលការណ៍ណែនាំនេះ ត្រូវបានរៀបចំឡើងជាបួនផ្នែកធំៗ ដែលផ្នែកនីមួយៗផ្តោតលើទិដ្ឋភាពនៃការរាយការណ៍ដែលគោរពតាមគោលការណ៍យេនឌ័រៈ

**គោលការណ៍គ្រឹះនៃសារព័ត៌មាន**

**ការជ្រើសយកប្រភព និងរឿង ដើម្បីឱ្យមានវត្តមាន និងការឱ្យតម្លៃស្មើគ្នារវាងស្ត្រី និងបុរស នៅក្នុងប្រព័ន្ធផ្សព្វផ្សាយក្នុងការឆ្លុះបញ្ចាំងសង្គមឱ្យបានគ្រប់ជ្រុងជ្រោយ**

**ការពណ៌នា ឬឆ្លុះបញ្ចាំងអំពីស្ត្រី និងបុរសដោយស្មើភាពគ្នាតាមរយៈការលុបបំបាត់នូវផ្នត់គំនិតចាស់គំរិល**

**ការប្រើប្រាស់ពាក្យពេចន៍ដោយគោរពតាមគោលការណ៍យេនឌ័រ**

## ៤.១ គោលការណ៍គ្រឹះ នៃសារព័ត៌មាន

គោលការណ៍គ្រឹះនៃសារព័ត៌មាន មានសារៈសំខាន់ណាស់នៅក្នុងគោលការណ៍ណែនាំស្តីពីការរាយការណ៍ដែលគោរពតាមសមភាពយេនឌ័រ។ អ្នកសារព័ត៌មាន មានទំនួលខុសត្រូវចំបងក្នុងការផ្តល់ជូនពលរដ្ឋនូវព័ត៌មានត្រឹមត្រូវ។ ពួកគេត្រូវប្រកាន់ខ្ជាប់យ៉ាងម៉ឺងម៉ាត់នូវគោលការណ៍គ្រឹះទាំងប្រាំពីរនេះៈ

| | |
|---|---|
| **ភាពត្រឹមត្រូវ** | ត្រូវសរសេរផ្អែកលើការពិត ។ |
| **ឯករាជ្យ** | មិនត្រូវធ្វើសកម្មភាពជាផ្លូវការ ឬក្រៅផ្លូវការដើម្បីទទួលបានប្រយោជន៍ពិសេសផ្ទាល់ខ្លួនអ្វី មួយឡើយ ហើយត្រូវតែប្រកាសឱ្យសាធារណជនដឹងនូវអ្វីដែលអាចបង្កឱ្យមានទំនាស់ផលប្រយោជន៍។ |
| **ភាពមិនលម្អៀង** | ត្រូវផ្តល់បរិបទនៃព័ត៌មានក្នុងសេចក្តីរាយការណ៍ ហើយបង្ហាញទស្សនៈចម្រុះ ដើម្បី ទទួលបានការជឿជាក់ និងការទុកចិត្ត ។ |
| **ការរក្សាការណ៍សម្ងាត់** | ការពារប្រភពសម្ងាត់របស់ខ្លួន ដើម្បីទទួលបានការជឿទុកចិត្តពីប្រភពព័ត៌មាន និងរក្សាសុវត្ថិភាពដល់ប្រភព។ |
| **មនុស្សធម៌** | បម្រើប្រយោជន៍សាធារណៈ និងគិតគូរដល់បញ្ហាដែលប្រឈមដោយក្រុមបាត់បង់ ឱកាស និងក្រុមងាយរងគ្រោះ។ |
| **គណនេយ្យភាព** | ចេញផ្សាយសេចក្តីកែតម្រូវភ្លាមៗឱ្យបានទូលំទូលាយ និងប្រកបដោយភាពស្មោះត្រង់នៅពេលដែលមានកំហុស។ |
| **តម្លាភាព** | ការរក្សានូវតម្លាភាព ធ្វើឱ្យយើងមានទំនួលខុសត្រូវ ហើយជួយដល់ការបង្កើត និងការរក្សា ជំនឿទុកចិត្តលើសារព័ត៌មាន ។ |

## ៤.២ ការជ្រើសយកប្រភព និងរឿង ដើម្បីឱ្យមានវត្តមាន និងការឱ្យតម្លៃស្មើគ្នារវាងស្ត្រី និងបុរស នៅក្នុងប្រព័ន្ធផ្សព្វផ្សាយក្នុងការឆ្លុះបញ្ចាំងសង្គមឱ្យបានគ្រប់ជ្រុងជ្រោយ

ដើម្បីទទួលបានសមភាពយេនឌ័របន្ថែមទៀតក្នុងខ្លឹមសារនៅក្នុងប្រព័ន្ធផ្សព្វផ្សាយ យើងគួរៈ

**យកចិត្តទុកដាក់ដើម្បីឱ្យមានវត្តមានរបស់ស្ត្រី និងបុរស ដែលត្រូវបានឃើញ បានឮ និងបានអានដោយស្មើភាពគ្នានៅក្នុងព័ត៌មាន និងកិច្ចការពាក់ព័ន្ធបច្ចុប្បន្ន។** សូមពិចារណាឱ្យបានខ្ពស់ផងដែរ ក្នុងការដាក់បញ្ចូល ឬ លើកយកមកនិយាយ នូវរឿងរ៉ាវ និងសំឡេងចម្រុះគ្នារបស់ប្រជាពលរដ្ឋ ជាពិសេសរឿងផ្សេងៗ ដែលស្ទើរតែមើលមិនឃើញនៅក្នុងសារព័ត៌មាន (ឧទាហរណ៍ៈ ស្ត្រីដែលស្ថិតក្នុងក្រុមដែលពុំសូវបានយកចិត្តទុកដាក់ ដូចជាស្ត្រីវ័យចំណាស់ ស្ត្រីជាជនជាតិភាគតិច ឬស្ត្រីជនជាតិដើមភាគតិច) ។

**បង្ហាញពីវត្តមានស្មើគ្នារវាងស្ត្រី និងបុរស សម្រាប់ការអធិប្បាយព័ត៌មាន និងការសម្របសម្រួលកិច្ចពិភាក្សា នៅលើប្រព័ន្ធផ្សព្វផ្សាយសារព័ត៌មានទាំង ទូរទស្សន៍ វិទ្យុ ព័ត៌មានអនឡាញ និងកម្មវិធីជជែកពិភាក្សានានា ។** សំខាន់ជាងនេះទៀត តួនាទីរបស់អ្នកអធិប្បាយព័ត៌មាន ឬ អ្នកសម្របសម្រួលក្នុងកម្មវិធីពិភាក្សាជាស្ត្រី និងជាបុរស គួរតែមានភាពស្មើគ្នា។ ឧទាហរណ៍ៈ អ្នកអានព័ត៌មាន អ្នកអធិប្បាយ ឬ អ្នកសម្របសម្រួលក្នុងកម្មវិធីពិភាក្សាជាស្ត្រី គួរត្រូវបានផ្តល់នូវឱកាសនិយាយក្នុងវិស័យដែលភាគច្រើនត្រូវបានទទួលខុសត្រូវដោយបុរស ដូចជាៈ វិស័យនយោបាយ និងរដ្ឋាភិបាល សេដ្ឋកិច្ច និងអាជីវកម្ម សង្គ្រាម និងជម្លោះ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ព្រមទាំងវិស័យកីឡាជាដើម ។

**យកចិត្តទុកដាក់លើវត្តមានប្រកបដោយភាពស្មើគ្នារវាងស្ត្រី និងបុរស នៅក្នុងព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយ គ្រប់វិស័យទាំងអស់** រួមទាំងយកចិត្តទុកដាក់ក្នុងការរាយការណ៍អំពីរឿងរ៉ាវ របស់ស្ត្រីនៅក្នុងវិស័យផ្សេងៗ (ជាពិសេសវិស័យដែលសំបូរដោយបុរស) ដូចជា នយោបាយ និង រដ្ឋាភិបាល សេដ្ឋកិច្ច និងធុរកិច្ច បញ្ហាសង្គ្រាម និងជម្លោះ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា កីឡា ។ល។

**យកចិត្តទុកដាក់លើការជ្រើសរើសប្រភពព័ត៌មានដោយមានវត្តមានស្មើគ្នារវាង ស្ត្រី និងបុរស ក្នុងការស្រង់យកមតិយោបល់ ព័ត៌មាន នៅក្នុងអត្ថបទសារព័ត៌មាន។** (ឧទាហរណ៍ យកចិត្តទុកដាក់លើប្រភពព័ត៌មានជាស្ត្រីដែលជាអ្នកជំនាញមិនមែនត្រឹមតែសម្ភាសស្ត្រីជាមនុស្សធម្មតាឬជនរងគ្រោះនោះទេ)។

**យកចិត្តទុកដាក់ថា ប្រភពរបស់អ្នកអាចតំណាងឱ្យមតិយោបល់ចម្រុះពីក្រុមមនុស្សផ្សេងៗគ្នា** រាប់បញ្ចូលទាំងក្រុមដែលពុំសូវបានយកចិត្តទុកដាក់ (ឧទាហរណ៍ ក្រុមអ្នកស្រឡាញ់ភេទដូចគ្នា ជនមានពិការភាព ជនជាតិដើមភាគតិច ។ល។) ប្រសិនបើមានពាក់ព័ន្ធ សូមពិគ្រោះយោបល់ជាមួយអង្គការ ដែលធ្វើការងារពាក់ព័ន្ធនឹងសិទ្ធិស្ត្រី សមភាពយេនឌ័រ និងក្រុមដទៃទៀតដែលពុំសូវបានយកចិត្តទុកដាក់ ដែលអាចតំណាងឱ្យក្រុមទាំងនោះបានក្នុងការផ្តល់នូវទស្សនៈ ប្រកបដោយបរិយាបន្ន និងសមភាព ។

**យកចិត្តទុកដាក់លើចំនួនរឿង ឬបញ្ហាដែលផ្តោតជាពិសេសលើស្ត្រី ឬ បញ្ហាណាដែលពាក់ព័ន្ធទៅនឹងការ បារម្ភរបស់ស្ត្រី** (ឧទាហរណ៍ អំពើហិង្សាផ្អែកលើយេនឌ័រ សិទ្ធិស្ត្រី សមិទ្ធផល ឬភាពជោគជ័យរបស់ស្ត្រី ។ល។) អ្នកក៏ត្រូវយកចិត្តទុកដាក់ទៅលើការយកព័ត៌មានពាក់ព័ន្ធទៅនឹងបញ្ហាសមភាព និងវិសមភាពយេឌ័រផងដែរ (គួរផលិត ឬសរសេររឿង ឬអត្ថបទព័ត៌មានជាក់លាក់ណាមួយអំពីសមភាព ឬ វិសមភាពយេនឌ័រ គោលនយោបាយ បញ្ហាច្បាប់ កម្មវិធី ដែលរៀបចំឡើងក្នុងន័យលើកកម្ពស់សមភាពយេនឌ័រ)។

## ៤.៣ ការពណ៌នា ឬ ការឆ្លុះបញ្ចាំងអំពីស្ត្រី និងបុរសដោយស្មើភាពគ្នាតាមរយៈការលុបបំបាត់នូវផ្នត់គំនិតចាស់គំរិល

ដើម្បីជានាបាននូវការឆ្លុះបញ្ចាំងអំពីស្ត្រី និងបុរសឱ្យបានត្រឹមត្រូវ ចូរព្យាយាម៖

**បង្ហាញពីព័ត៌មាន ឬការពិពណ៌នាត្រឹមត្រូវ ទាក់ទងទៅនឹងការឆ្លុះបញ្ចាំងពីវត្តមាន និងសមភាពយេនឌ័រ។** ចៀសវាងការដាក់បញ្ចូលផ្នត់គំនិតមិនត្រឹមត្រូវ រួមទាំងការបកស្រាយពី ចរិត និងតួនាទីរបស់ស្ត្រីនៅក្នុងសង្គម។ លើសពីនេះទៀត ព្យាយាមលុបបំបាត់ការសន្មត់ ដោយផ្អែកទៅលើភេទ រួមទាំងការពិពណ៌នាបែបចាស់គំរិល ដូចជាចរិតលក្ខណៈជាស្ត្រី / ចរិតលក្ខណៈជាបុរស និងតួនាទីរបស់បុរស និងស្ត្រី)។ ចៀសវាងការរៀបរាប់អំពីការងារ ឬតួនាទីណាមួយ ដែលបង្ហាញថាការងារនោះសម្រាប់តែបុរស ឬ សម្រាប់តែស្ត្រី (ឧទាហរណ៍ កសិករជាបុរស គ្រូបឋមគឺជាស្ត្រី ឬ ប្រើផ្នត់គំនិតចាស់គំរិលក្នុងការពណ៌នា តួនាទីយេនឌ័រ ដូចជាការបង្ហាញថាស្ត្រីជាម្តាយ អ្នកធ្វើការងារផ្ទះ ។ល។)

**បង្ហាញ ឬ ពណ៌នាពីបុគ្គលស្មើភាពគ្នា ដោយមិនគិតពីតួនាទីសង្គមរបស់ពួកគេ ដែលអាចបង្កឱ្យមានការសន្មត់ថាភេទមួយ មិនមានឥទ្ធិពលជាងភេទផ្សេងទៀត។** កុំបង្ហាញអំពីចរិតលក្ខណៈយេនឌ័ររបស់ស្ត្រី និងបុរស។ ឧទាហរណ៍ កុំរៀបរាប់ថា ក្មេងស្រីមានភាពអៀនខ្មាស់ ហើយក្មេងប្រុសតែងតែមានភាពអង់អាចក្លាហាន។ បុរសតែងត្រូវបានគេកោតសរសើរចំពោះសមិទ្ធផលរបស់ពួកគេ ចំណែកស្ត្រីតែងត្រូវបានសរសើរចំពោះរូបរាងកាយ។ ស្ត្រីជាអ្នករងអំពើ ចំណែកបុរសជាអ្នកធ្វើអំពើ។ ក្នុងករណីឧក្រិដ្ឋកម្ម អំពើហិង្សា គ្រោះមហន្តរាយផ្សេងៗ កុំបង្ហាញថាស្ត្រីតែងតែជាជនរងគ្រោះ ហើយលើកតម្កើនបុរសតែងតែជាអ្នកតស៊ូ ឬជាអ្នកជម្នះគ្រប់បញ្ហា។

**គួរតែបញ្ចូលរឿងរ៉ាវដែលបង្ហាញពីវត្តមាន ពហុភាគី / ការបង្ហាញពីបុរស និងស្ត្រី** (បង្ហាញពីកិច្ចប្រឹងប្រែង ការប្រជែង ឬ ការប្រឆាំងនឹងផ្នត់គំនិតចាស់គំរិលទៅលើយេនឌ័រ) ។

**សូមចៀសវាងការពណ៌នាអំពីភេទនៅក្នុងសារព័ត៌មានគ្រប់ប្រភេទ រួមបញ្ចូលទាំងនៅក្នុងអត្ថបទសំឡេង វិទ្យុ វីដេអូ និងរូបភាព ជាពិសេសការពណ៌នាស្ត្រីជាវត្ថុសម្រាប់ចំណង់ផ្លូវភេទ។** បន្ថែមពីនេះទៀត សូមយកចិត្តទុកដាក់ ក្នុងការធ្វើឱ្យមានសមភាពយេនឌ័រ ក្នុងការផ្សាយដែលបង្ហាញថាស្ត្រី និងបុរសមានភាពរឹងមាំដូចគ្នា នៅក្នុងការផ្សាយពាណិជ្ជកម្ម សារ និងរូបភាពផ្សេងៗ។

**គួរតែបង្ហាញរូបភាពបុរស និងស្ត្រី ក្នុងការផ្សាយពាណិជ្ជកម្ម សារ និងរូបភាព ផ្សេងៗ ដោយស្មើភាពគ្នា។ ព្យាយាមកាត់បន្ថយការផ្សព្វផ្សាយពាណិជ្ជកម្ម សម្រាប់ប្រភេទផលិតផល ឬសេវាកម្មផ្សេងៗដែលបង្ហាញពីតួនាទីយេនឌ័រ** (ឧទាហរណ៍ ភាគច្រើនលើសលប់ ស្ត្រីត្រូវបានបង្ហាញ នៅក្នុងការផ្សព្វផ្សាយផលិតផលទំនិញផ្សេងៗទាក់ទងនឹង ការងារផ្ទះ ភេសជ្ជៈ យានយន្ត ផលិតផលសម្រាប់កុមារ សម្អាតផ្ទះបាយ ក៏ដូចជាសេវាកម្មក្នុងការអប់រំសុខភាព ការថែទាំកុមារ ចំណែកឯបុរសតែងតែបង្ហាញវត្តមាននៅក្នុងវិស័យធនាគារ និងការវិនិយោគ អចលនទ្រព្យ ព្រឹត្តិការណ៍កីឡាផ្សេងៗ)។

## ៤.៤ ការប្រើប្រាស់ពាក្យពេចន៍ដែលគោរពតាមគោលការណ៍យេនឌ័រ

| ពាក្យដែលគួរប្រើ | ពាក្យដែលមិនគួរប្រើ |
| --- | --- |
| គួរប្រើប្រាស់ពាក្យពេចន៍ដែលគោរពតាមគោលការណ៍យេនឌ័រ សម្រាប់ការបង្ហាញមុខងារ ឬមុខរបរណាមួយ ក្នុងន័យជំរុញឱ្យមានសមភាពយេនឌ័រ រវាងស្ត្រីនិងបុរស។ ឧទាហរណ៍ គួរប្រើពាក្យដូចជា អ្នកធ្វើការនៅក្នុងវិស័យកម្សាន្ត ជាជាងស្ត្រីបម្រើការ KTV។ | គួរចៀសវាងការប្រើប្រាស់ពាក្យពេចន៍សម្រាប់មុខងារ ឬមុខរបរណាមួយ ដែលឆ្លុះបញ្ចាំងពីភាពមិនស្មើភាពគ្នា ឬបន្ទាបតម្លៃ បុរសនិងស្ត្រី។ ឧទាហរណ៍ មិនគួរប្រើពាក្យដូចជា ស្ត្រីបម្រើការ KTV។ |
| ត្រូវគោរពតាមក្រមសីលធម៌នៅពេលជ្រើសរើសចំណងជើងសម្រាប់អត្ថបទ។ ចំណងជើងអត្ថបទគួរបង្ហាញព័ត៌មានពិតដែលឆ្លុះបញ្ចាំងពីអត្ថបទទាំងមូល។ | ចៀសវាងការប្រើចំណងជើងដែលមានពាក្យពេចន៍អាសអាភាស មិនសមរម្យ មិនជាការពិត ដើម្បីទាក់ទាញអ្នកអានឱ្យកាន់តែច្រើន។ |
| គួរប្រើប្រាស់ពាក្យពេចន៍ ឬឃ្លាឃ្លោងសមស្របនៅក្នុងអត្ថបទព័ត៌មានដើម្បីលើកកម្ពស់វប្បធម៌ និងសង្គម។ | ចៀសវាងការប្រើប្រាស់ពាក្យពេចន៍ ឬឃ្លាឃ្លោង មិនសមរម្យដោយផ្ទាល់ ឬប្រយោល ដើម្បីពិពណ៌នា អវយវៈភេទ ឬសកម្មភាពផ្លូវភេទណាមួយ សម្រាប់ការកម្សាន្ត បន្ទាបតម្លៃ បន្ទោស បង្អាប់។ ឧទាហរណ៍ មិនគួរប្រើពាក្យដូចជា ការបរិយាយអវយវៈភេទ ជាមួយនឹងនំអាកោរ ជាដើម ។ល។ |
| បរិយាយ ឬពណ៌នា ដំណើររឿង ឬបុគ្គល តាមការពិត ដែលឱ្យអ្នកអានជាអ្នកធ្វើសេចក្តីសន្និដ្ឋានដោយខ្លួនឯង។ | ចៀសវាងការបរិយាយ ឬពណ៌នា ដំណើររឿង ឬបុគ្គលដោយបញ្ចូល ការយល់ឃើញ ការវាយតម្លៃ ឬការសន្និដ្ឋានណាមួយរបស់អ្នកសរសេរ ជាពិសេសទៅលើការឱ្យតម្លៃយេនឌ័រ។ ឧទាហរណ៍ មិនគួរប្រើពាក្យដូចជា ស្ត្រីស្រស់ស្អាត ស្ត្រីទន់ខ្សោយ បុរសកំណាច ។ល។ កុំបញ្ចូលការសន្និដ្ឋាននានាទៅលើជនសង្ស័យ ឬជនជាប់ចោទ ដូចជាដោយសារតែភ្លើងតណ្ហា ការច្រណែន និងការមើលងាយ។ |
| ព័ត៌មានត្រូវមានលក្ខណៈអព្យាក្រឹត និងផ្តល់បរិបទ និងបង្ហាញពីទស្សនៈផ្សេងគ្នាដើម្បីបង្កើត ការជឿជាក់ និងទំនុកចិត្តទៅលើការរាយការណ៍ព័ត៌មាននោះ។ | ចៀសវាង ការបរិយាយ ឬការប្រើប្រាស់ពាក្យពេចន៍ ញុះញង់ស្តីបន្ទោស ឬដាក់បន្ទុកដល់ស្ត្រី ឬបុរស ដែលជាជនរងគ្រោះ ក្នុងអំពើហិង្សា។ ឧទាហរណ៍ មិនគួរបន្ថែមការសន្និដ្ឋាន វិភាគ ឬយោបល់ របស់អ្នកសរសេរ ទៅលើសម្លៀកបំពាក់ របៀបរស់នៅ របរចិញ្ចឹមជីវិត ភេទ ពេលវេលា ឬទីកន្លែង ថាអាចជាដើមហេតុក្នុងអំពើហឹង្សានោះ។ |
| ប្រព័ន្ធផ្សព្វផ្សាយត្រូវប្រើភាសាសមរម្យ និង ត្រឹមត្រូវដើម្បីលើកកម្ពស់សេចក្តីថ្លៃថ្នូររបស់ប្រភព ឬជនរងគ្រោះ | ចៀសវាងប្រើប្រាស់ពាក្យពេចន៍មួយចំនួន ដូចជា «ទំនាក់ទំនងប្រេះឆា, ខ្ជិល, ខ្មាសអៀន, ផិតក្បត់, ចំណង់ផ្លូវភេទខ្លាំង» និង ភាសាដែលធ្វើឱ្យប៉ះពាល់កិត្តិយសផ្សេងទៀតដែលមិនសមរម្យ ជាពិសេសនៅពេលពិពណ៌នាអំពីអំពើហិង្សាផ្លូវភេទលើស្ត្រី។ |

| ពាក្យដែលគួរប្រើ | ពាក្យដែលមិនគួរប្រើ |
|---|---|
| អ្នកសរសេរអត្ថបទគួរណាតែពណ៌នា ស្ត្រី និងបុរស ឱ្យស្មើភាពគ្នា ដោយមិនគិតពីតំណែង ទំនាក់ទំនងគ្រួសារ របរ វិជ្ជាជីវៈ ការសិក្សា និង ឋានៈជាដើម ។ល។ | ចៀសវាងការប្រើពាក្យពេចន៍ ដែលជំរុញឱ្យមានការបន្ទាបតម្លៃ បិទបាំង មិនឆ្លុះបញ្ចាំងពីអំណាចស្ត្រី ឬធ្វើការពណ៌នាឬសន្និដ្ឋានជារួមសម្រាប់ក្រុមមនុស្សណាមួយ។ ឧទាហរណ៍ គួរកុំប្រើពាក្យដូចជា «ប្រពន្ធលោកឧកញ៉ា» នៅពេលនិយាយដល់ប្តីឬប្រពន្ធរបស់នរណាម្នាក់។ លើកលែងករណីដែលពាក់ព័ន្ធទៅនឹងទំនាស់ផលប្រយោជន៍សាធារណៈ។ |
| ត្រូវគោរពតាមក្រមសីលធម៌នៅពេលជ្រើសរើសចំណងជើងសម្រាប់អត្ថបទ។ ចំណងជើងអត្ថបទគួរបង្ហាញព័ត៌មានពិតដែលឆ្លុះបញ្ចាំងពីអត្ថបទទាំងមូល។ | ចៀសវាងការប្រើចំណងជើងដែលមានពាក្យពេចន៍អាសអាភាស មិនសមរម្យ មិនជាការពិត  ដើម្បីទាក់ទាញអ្នកអានឱ្យកាន់តែច្រើន។ |
| ការព្រមព្រៀងត្រូវណែនាំឱ្យច្បាស់លាស់ និង ឯកភាពរវាងអ្នកយកព័ត៌មាន និងប្រភព មុនពេលការសម្ភាស ចាប់ផ្តើម ជាពិសេសនៅពេលពិពណ៌នាអំពីឈុតឆាករំលោភបំពាន ឬ អំពើហិង្សា។ ការព្រមព្រៀងនេះក៏អនុវត្តចំពោះការប្រើប្រាស់សម្រង់សំដី រូបថត សំឡេង និង វីដេអូផងដែរ។ សម្រាប់ប្រភពជាអនីតិជន អ្នកយកព័ត៌មានគួរតែសុំការយល់ព្រមពីអាណាព្យាបាល ឬ ពុកម្តាយរបស់ពួកគេ។ | គួរចៀសវាងការដកស្រង់សំដី ឬប្រើប្រាស់រូបថត សំឡេង ឬ វីដេអូណាមួយដោយគ្មានការយល់ព្រមជាមុន ជាពិសេសប្រសិនបើប្រភពរបស់អ្នក ជាអនីតិជន ជាជនងាយរងគ្រោះ និងក្រុមដែលមិនស្រួវត្រូវបានយកចិត្តទុកដាក់។ |
| សម្រាប់ការរាយការណ៍ អំពីអំពើហិង្សាលើស្ត្រី អ្នកសរសេរគួរតែគោរពតាម ក្រមប្រតិបត្តិប្រព័ន្ធផ្សព្វផ្សាយសម្រាប់ការរាយការណ៍ព័ត៌មានអំពើហិង្សាលើស្ត្រី | អ្នករាយការណ៍ មិនគួររាយការណ៍ព័ត៌មានដែលរៀបរាប់លម្អិត បង្ហាញខ្លឹមសារលម្អិតឬរូបភាពលម្អិត អំពីសកម្មភាពហិង្សាពាក់ព័ន្ធនឹងអំពើហិង្សាលើស្ត្រី ឬអំពើរំលោភសេពសន្ថវៈដែលបង្កឱ្យមានភាពតានតឹងក្នុងអារម្មណ៍ ចំពោះអ្នកអាន អ្នកស្តាប់ អ្នកទស្សនា ឬអ្នកពាក់ព័ន្ធនោះទេ។ |

## ឯកសារយោង

NGO-CEDAW Gender Policy as of 5 September 2019 GSDRC.org.

Gender and Media. 2015

Luba Kassova. The Missing Perspectives of Women in News. 2020

FOJO Media Institute. The Gender-in-Media Landscape Study (Cambodia). 2018

UNESCO. Gender sensitive reporting.

UNESCO. Gender-Sensitive Indicators for Media. Framework of Indicators to Gauge Gender Sensitivity in Media Operations and Content. Paris, 2012.

UNDP Gender Equality Seal initiative. Principles of Gender Sensitive Communication.

Ministry of Information and Ministry of Women Affair. Media Code of Conduct for Reporting on Violence Against Women (English Translation). 2017

The United Nations. Gender Inclusive Language. https://www.un.org/en/gender-inclusive-language/







អ្នកចូលរួមមកពីវិស័យសារព័ត៌មាន រដ្ឋាភិបាល អ្នកសិក្សា និងសង្គមស៊ីវិល ដែលបានចំណាយពេលវេលាចូលរួម និងផ្តល់នូវធាតុចូល និងអនុសាសន៍សំខាន់ៗ លើគោលការណ៍ណែនាំនៅក្នុងសិក្ខាសាលាពិគ្រោះយោបល់តាមប្រព័ន្ធអ៊ីនធឺណែត។




ក្រុមការងារគម្រោងគំនិតផ្តួចផ្តើមឱ្យមានការផ្លាស់ប្តូរនៅកម្ពុជា
កម្មវិធីបណ្តុះបណ្តាលអន្តរជាតិ ស្តីពីការអភិវឌ្ឍន៍ប្រព័ន្ធផ្សព្វផ្សាយនៅក្នុង
ក្របខ័ណ្ឌប្រជាធិបតេយ្យក្នុងតំបន់អាស៊ីឆ្នាំ២០២០